ជូនចំពោះមាតាបិតា ឬ អ្នកបីបាច់ថែរក្សារ:

សាលា_____ផ្តល់ជូនទូវចំណីអាហារមានសុខភាពល្អ
រាល់ថ្ងៃរៀន ។ កូនក្មេងអាចទិញអាហារស្រស់ស្រួបពេលថ្ងៃត្រង់ តម្លៃ_____ និងម្ហូបស្រស់ស្រួបពេលព្រឹក
តម្លៃ_____ ។ កូនក្មេងដែលគ្រប់លក្ខណៈ នៅក្រោមគោលការណ៍នាំ របស់ក្រសួងកសិកម្មសហរដ្ឋអាមេរិក
អាចទទួលបានចំណីអាហារ ដោយមិនបាច់បង់ថ្លៃ ឬ ដោយការបញ្ចុះតម្លៃ ឱយនៅត្រឹម_____
សម្រាប់អាហារថ្ងៃត្រង់ និង តម្លៃ_____ សម្រាប់អាហារពេលព្រឹក ។ អាហារទាំងអស់ចាំបាច់ត្រូវតែ
មានលក្ខណៈជីវជាតិ ស្របតាមការតម្រូវ បង្កើតឡើងដោយ ក្រសួងកសិកម្មសហរដ្ឋអាមេរិក ។
ប្រសិនបើកូនក្មេងណាម្នាក់មានការពិការអ្វីមួយ តាមការសម្រេចរបស់វេជ្ជបណ្ឌិតម្នាក់នោះ ហើយការពិការនោះ
រារាំងមិនឱយក្មេងនោះទទួលទានអាហារធម្មតារបស់សាលានោះ សាលានិងរកម្ហូបអាហារ ដែលវេជ្ជបណ្ឌិតបញ្ជា
មកជំនួសវិញ ។ ប្រសិនបើមានសេចក្តីត្រូវការប្តូរម្ហូបអាហារ និងគ្មានការយកប្រាក់អ្វីបន្ថែមទេ ។
ក៏ប៉ុន្តែសូមកត់សម្គាល់ថា សាលាមិនតម្រូវឱយប្តូរម្ហូបអាហារ សម្រាប់ការទាស់ម្ហូបអ្វីមួយទេ
ជ្បៀរលែងតែម្ហូបនោះស្របទៅតាមអត្ថន័យ នៃការពិការ ។ សូមទូរសព្ទ័ទៅកាន់សាលា
ដើម្បីទទួលពត៌មានបន្ថែមទៀត ។

កូនរបស់លោកអ្នក អាចទទួលបានចំណីអាហារសាលា ដោយមិនចាំបាច់បង់ថ្លៃ ប្រសិនបើលោកអ្នកទទួលប្រាក់
FOOD STAMP ប្រាក់ជំនួយបណ្តោះអាសន្ន៍សម្រាប់គ្រួសារខ្វះខាត(TANF) ឬ កម្មវិធីចែកចាយម្ហូបអាហារ
សម្រាប់អ្នករស់នៅកន្ទែងជនជាតិ INDIAN (FDPIR) នោះ ។
ប្រសិនបើប្រាក់ចំណូលទាំងអស់ក្នុងគ្រួសារលោកអ្នក មានចំនួនស្មើ ឬ តិចជាងចំនួន
នៅលើតារាងប្រាក់ចំណូលនោះ កូនលោកអ្នកអាចទទួលចំណីអាហារ
ដោយមិនចាំបាច់បង់ថ្លៃឬមួយក៏ដោយបង់មិនពេញថ្លៃ ។

Cambodian